**មជ្ឈមណ្ឌលដើម្បីសន្តិភាព និង អភិវឌ្ឍន៍**

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

Centre for Peace and Development (CPD)
Cambodia Development Resource Institute (CDRI)

# កំណត់ហេតុកិច្ចប្រជុំខប់សែលប្រ៉ែម តំបន់ទី ៧

# យន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា ដំណាក់កាលទី ២

**ថ្ងៃសុក្រ ទី១៥ ខែធ្នូ ឆ្នាំ២០០៦**

**ខេត្តកោះកុង**

**ខប់សែល ដំណាក់កាលទី ២**

**COPCEL Phase II**

*ឧបត្ថម្ភដោយ / Sponsored by*

**កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ**

**United Nations Development Programme (UNDP)**

## របៀបវារៈនៃកិច្ចប្រជុំ

០១.ចំណាប់អារម្មណ៍ស្វាគមន៍ដោយ ឯកឧត្តម **យ៉យ ស៊ើយ** អភិបាលរង ខេត្តកោះកុង

០២.ចំណាប់អារម្មណ៍ស្វាគមន៍ដោយ លោក **ដួង វីរ័ត្ន** ប្រធានកម្មវិធី សន្តិសុខមនុស្ស និងការកសាងសន្តិភាព និងជាតំណាង លោក **ឡារី ស្ត្រេនួ (Larry Strange)** នាយកប្រតិបត្តិ នៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)

០៣.បទអន្តរាគមន៍ស្តីពីយន្តការខប់សែលប្រ៉ម (COPCELPROM) ដោយលោក **ឱក សេរី សោភក្តិ៍** ទីប្រឹក្សា និងជាអ្នកសំរបសំរួលយន្តការខប់សែល នៃវិទ្យាស្ថាន CDRI

០៤. ស្ថានភាពទូទៅនៃការរៀបចំការបោះឆ្នោត ថ្លែងដោយ លោក **សេង នេង** ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តកោះកុង

០៥. មតិរបស់អ្នកចូលរួមដែលបង្ហាញអំពីការប្រឈមទាំងឡាយក្នុងយន្តការរៀបចំការបោះឆ្នោតក្នុងបរិបទខេត្តកោះកុង

០៦. សេចក្តីផ្សេងៗ

### ០១. ចំណាប់អារម្មណ៍ស្វាគមន៍ដោយ ឯកឧត្តម យ៉យ ស៊ើយ អភិបាលរង ខេត្តកោះកុង

ឯកឧត្តម **យ៉យ ស៊ើយ** អភិបាលរងខេត្តកោះកុង បានធ្វើការស្វាគមន៍ និងសូមអរគុណដល់លោក ដួង វីរ័ត្ន ដែលជាតំណាងលោក ឡារី ស្ត្រេនួ លោក ឱក សេរី សោភក្តិ៍ ជាទីប្រឹក្សា និងជាអ្នកសំរបសំរួលកម្មវិធីខប់សែល និងសមាជិកអង្គប្រជុំទាំងអស់ ។ ឆ្លៀតក្នុងឱកាសនេះ ឯកឧត្តម សូមសំដែងនូវការរំភើបរីករាយយ៉ាងក្រៃលែង ដែលបានចូលរួមនៅក្នុងកិច្ចប្រជុំស្តីពី យន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជាសំរាប់ ខេត្តកោះកុង ។ ឯកឧត្តម សូមឱ្យសមាជិកអង្គប្រជុំទាំងអស់ពិភាក្សាឱ្យ បានផុលផុស ។

### ០២. ចំណាប់អារម្មណ៍ស្វាគមន៍ដោយ លោក ដួង វីរ័ត្ន ប្រធានកម្មវិធី សន្តិសុខមនុស្ស និងការកសាងសន្តិភាព និងជាតំណាង លោក ឡារី ស្ត្រេនួ (Larry Strange) នាយកប្រតិបត្តិនៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍ កម្ពុជា (CDRI)

លោក **ដួង វីរ័ត្ន** ប្រធានកម្មវិធី សន្តិសុខមនុស្ស និងការកសាងសន្តិភាព ក្នុងនាមជាតំណាង **លោក ឡារី ស្ត្រេនួ** នាយកប្រតិបត្តិនៃវិទ្យាស្ថាន CDRI បានធ្វើការស្វាគមន៍ និងថ្លែងអំណរគុណដល់សមាជិកនៃអង្គប្រជុំទាំងមូល ដែលបានចំណាយពេលវេលាដ៏មានតម្លៃអញ្ជើញចូលរួមនៅក្នុងកិច្ចប្រជុំនេះ ។ លោក ក៏សូមថ្លែងអំណរគុណដល់ ឯកឧត្តម យុទ្ធ ភូថង ដែលបានគាំទ្រ និងជួយសំរួលរាល់ការងាររបស់វិទ្យាស្ថាន CDRI ដើម្បីឱ្យមានការរៀបចំកិច្ចប្រជុំនេះឡើង ។ លោក សូមជូនពរឱ្យកិច្ចប្រជុំទទួលបាននូវផ្លែផ្កា ព្រមទាំងមានការពិភាក្សាយ៉ាងផុលផុសពីសំណាក់អង្គប្រជុំទាំងមូល ។

### ០៣. បទអន្តរាគមន៍ស្តីពីយន្តការខប់សែលប្រ៉ម (COPCELPROM) ដោយលោក ឱក សេរី សោភក្តិ៍ ទីប្រឹក្សា និង ជាអ្នកសំរបសំរួលយន្តការខប់សែល នៃវិទ្យាស្ថាន CDRI

នៅពេលដែលលោកត្រឡប់មកពីធ្វើការជាពេទ្យនៅជាយដែនវិញ បានឃើញទុក្ខសោករបស់បងប្អូនប្រជាពលរដ្ឋច្រើនណាស់នៅតាមជាយដែន ។ ក្រោយពីប្រទេសកម្ពុជាទទួលរងនូវការដឹកនាំបៀបប្រល័យពូជសាសន៍ជំនាន់ប៉ុលពតជាច្រើនឆ្នាំ ហើយ

ក៏បន្តសោកនាដកម្មមិនចេះចប់ មិនចេះហើយ ។ លោក តែងតែគិតនៅក្នុងចិត្តថា នៅស្រុកខ្មែររបស់យើង តើថ្ងៃណាបានបញ្ចប់នៅការកាប់សម្លាប់គ្នា បញ្ចប់សង្គ្រាម ភាពហិនហោច ។ ដោយមានការស្នើពីសម្តេច ហ៊ុន សែន និងឯកឧត្តម ស ខេង ឱ្យចូលរួមនៅក្នុងរាជរដ្ឋាភិបាល លោកក៏បានធ្វើជាទីប្រឹក្សា និងជានាយខុទ្ទកាល័យរបស់ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី ពីឆ្នាំ ១៩៩៣ ដល់ឆ្នាំ ១៩៩៨ ។ លោកក៏បានទទួលការងាររៀបចំការបោះឆ្នោតនៅឆ្នាំ ១៩៩៨ ដោយ លោក បានរៀបចំជាមួយប្រទេសមួយចំនួនដើម្បីរៀបចំការបោះឆ្នោតដោយខ្មែរខ្លួនឯង ។ យើងចាប់ផ្តើមនៅឆ្នាំ ១៩៩៤ ដោយមានការសស្រាក់សស្រាំយ៉ាងខ្លាំង រហូតដល់មានបញ្ហានៅឆ្នាំ ១៩៩៧ សឹងតែធ្វើឱ្យយន្តការបោះឆ្នោតនៅឆ្នាំ ១៩៩៨ ពិបាកដំណើរការ ប៉ុន្តែយើងនៅតែជំនះធ្វើឱ្យទាល់តែបាន ។

ក្រោយពីធ្វើការជាមួយរាជរដ្ឋាភិបាលបាន ៥ឆ្នាំ លោកក៏ទៅធ្វើការជាមួយវិទ្យាស្ថាន CDRI ដើម្បីបានបទពិសោធន៍ការងារក្រៅរដ្ឋាភិបាល ។ លោក គិតថា ៥ឆ្នាំធ្វើការជាមួយរដ្ឋ ៥ឆ្នាំធ្វើការក្រៅរដ្ឋ ៥ឆ្នាំធ្វើការជាទីប្រឹក្សាឱ្យអង្គការអន្តរជាតិធំៗ និងពីឆ្នាំ ១៩៩៩-២០០៣ លោក បានធ្វើការជាអ្នកសំរបសំរួលឱ្យវិទ្យាស្ថាន CDRI ក្នុងកម្មវិធីដើម្បីអភិវឌ្ឍន៍ និងសន្តិភាព ។ ពេលនោះលោកក៏បានធ្វើការស្រាវជ្រាវថា តើការបោះឆ្នោតឆ្នាំ ១៩៩៨ ហេតុអ្វីបានជាមានអំពើហិង្សាយ៉ាងច្រើនកើតឡើង? ហេតុអ្វីបានរូបភាពរបស់ប្រទេសកម្ពុជាយើងត្រូវទូរទស្សន៍ CNN បញ្ចាំងទៅពេញសកលលោកឱ្យឃើញថា ប្រទេសកម្ពុជា ជាប្រទេសមួយដែលមានអំពើហិង្សា ពេលបោះឆ្នោតម្តងៗមានការឈ្លោះប្រកែកគ្នា រហូតដល់មានការកាប់សម្លាប់ទៀត ។

ក្នុងន័យនេះហើយដែលលោកផ្ទាល់បានចាប់ផ្តើមរៀបចំយន្តការ ខប់សែល នេះឡើង ដើម្បីនឹងអញ្ជើញតួរអង្គទាំងអស់ដែលពាក់ព័ន្ធទាំងរាជរដ្ឋាភិបាល ក្រៅរាជរដ្ឋាភិបាល សង្គមស៊ីវិល គណបក្សនយោបាយ និងអង្គការអន្តរជាតិធំៗ ឱ្យអង្គុយជាមួយគ្នា ដូចដែលយើងកំពុងអង្គុយប្រជុំអញ្ចឹង ប៉ុន្តែធ្វើនៅថ្នាក់ជាតិពីឆ្នាំ ១៩៩៩-២០០៣ ។ ខប់សែល ប្រជុំដំបូងបំផុតនៅថ្ងៃ ២៦ ខែសីហា ឆ្នាំ ១៩៩៩ ដោយនេះជាការសាកល្បង ។ យន្តការ ខប់សែល នេះបង្កើតឡើងដោយដៃខ្មែរសុទ្ធសាធ មិនមានបរទេសចូលរួមទេ នេះគឺជាមោទនៈភាពមួយដែលយើងអាចរួបរួមគ្នាបាន ។ គ្រាន់តែចាប់ផ្តើមឡើង គឺមានការគាំទ្រយ៉ាងខ្លាំងពី សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង សម្តេចក្រុមព្រះនរោត្តមរណឫទ្ធិ ឯកឧត្តម សម រង្ស៊ី ឯកឧត្តម អ៊ឹម សួស្តី ។ ដោយយល់ឃើញថា យន្តការនេះអាចនឹងបង្កើតឱ្យមានវប្បធម៌ថ្មីមួយ គឺវប្បធម៌នៃការជជែកពិភាក្សាគ្នា ។ យន្តការនេះបានប្រជុំ ៥០ដង ពីឆ្នាំ ១៩៩៩-២០០៣ ដោយធ្វើតែនៅថ្នាក់ជាតិទេ ។

ក្រោយពីការសាកល្បងបានជោគជ័យរយៈពេល ៤ឆ្នាំ ហើយត្រូវឈានទៅដល់ការបោះឆ្នោតឆ្នាំ ២០០៧-២០០៨ ខាង UNDP ជាពិសេសលោក Douglas Gardner បានអានរបាយការណ៍របស់ខប់សែល ហើយគិតថា ជាការកម្រណាស់ដែលប្រទេសមួយ ទើបតែចេញពីសង្គ្រាម ហើយអាចរកឃើញដោយខ្លួនឯងនូវយន្តការដែលបង្កើតវប្បធម៌នៃការពិភាក្សាគ្នាត្រង់ទៅត្រង់មកនៅលើប្រធានបទក្តៅគគុក ដែលទាក់ទងនិងការបោះឆ្នោត ។ លោក Douglas Gardner ក៏បានមកជួបលោក ឡារី ស្ត្រេន្ទ និងលោកផ្ទាល់ សុំឱ្យធ្វើបន្តទៅទៀត ដើម្បីបំរើការបោះឆ្នោតឆ្នាំ ២០០៧-២០០៨ ។ លោក ផ្ទាល់បានគិតបន្តទៀតថា ទំនាស់ពិតប្រាកដដែលបានកើតឡើង ជួនកាលជាទំនាស់តូចតាចនៅថ្នាក់មូលដ្ឋាន បើសិនយើងក្តាប់ ឬគ្រប់គ្រងទំនាស់ទាំងអស់នេះបាន ជាពិសេសនៅថ្នាក់ភូមិឃុំ គឺយន្តការនៃការបោះឆ្នោតរបស់យើង នឹងក្លាយទៅជាយន្តការមួយដែលអាចនឹងចូលរួមដោយតួរអង្គទាំងអស់អាចគ្រប់គ្រងបាន ។ លោកក៏បំបែកយន្តការ ខប់សែល ហ្នឹងឱ្យទៅជាខប់សែលប្រ៉ម ដែល ខប់សែលបានធ្វើ ១៩ដងរួចមកហើយ។ ដើមឆ្នាំក្រោយ ខប់សែល នឹងទៅធ្វើនៅ ៤ខេត្តទៀតដើម្បីសំរេច ។ ដល់ឆ្នាំ ២០០៨ ខប់សែលនឹងធ្វើមួយជុំទៀត ដូច្នេះមួយខេត្តៗធ្វើ ២ដង មួយសំរាប់ក្រុម ប្រឹក្សាឃុំ សង្កាត់ មួយសំរាប់បោះឆ្នោតថ្នាក់ជាតិ ។

ខុប់សែលចង់ឮពីបញ្ហាដែលយើងមាន ហើយមានតែក្រុមប្រឹក្សាឃុំសង្កាត់ទេដែលនៅជិតនិងប្រជាពលរដ្ឋ ដែលស្គាល់កិច្ចការរឿងអ្វីដែលកើតឡើងជាមួយប្រជាពលរដ្ឋ ។ ដូច្នេះក្រុមប្រឹក្សាឃុំសង្កាត់អាចជំរាបជូនអង្គប្រជុំបាន ដោយមានភាពសុក្រឹត្យ ដោយជាក់លាក់ថា បញ្ហាអ្វីខ្លះដែលកើតឡើង ។ នេះជាគោលគំនិត ជាទស្សនៈទាននៃការបង្កើតយន្តការខុប់សែលនេះឡើង ។

អ្នកស្រី Margie Cook ប្រធានខាងអភិបាលកិច្ចនៅ UNDP ក៏បានចូលរួមខុប់សែលប្រ៊ែមនៅខេត្តក្រចេះ ខេត្តកំពង់ចាម ហើយអ្នកដំណាងខាងប្រទេស ស៊ុយអែត បានទៅចូលរួមនៅខេត្តកំពង់ឆ្នាំង ។ គេជឿហើយគេឱ្យលុយមកធ្វើ តែគេចង់ឃើញថាតើប្រជាធិបតេយ្យរស់រវើកតាមរយៈយន្តការខុប់សែលយ៉ាងណា? ដល់ទៅមើលផ្ទាល់បានគាត់ថា មិនមានប្រទេសឯទៀតៗដែលគាត់ធ្លាប់ធ្វើការជាមួយ មិនមានយន្តការបែបនេះទេ គាត់បានសរសើរប្រាប់អង្គទូតនានា ។ ខុប់សែល មិនដែលមានបញ្ហារឿងថវិការទេនៅក្នុងការធ្វើកិច្ចការនេះ ដោយសារនេះជាសកម្មភាពដែលខ្មែរធ្វើដោយដៃខ្លួនឯង ហើយបរទេសយកទៅចម្លង ។ ខាងទីម័រខាងកើត អាហ្វហ្គានីស្ថាន និងមានប្រទេស២ទៀត ក៏បានមកជួបលោក ដើម្បីសុំសិក្សាអំពីយន្តការខុប់សែលនេះ ។

យន្តការខុប់សែលប្រ៊ែម និងខុប់សែលនៅថ្នាក់ជាតិមានគោលដៅធំៗ ៣

**ទី១** ចង់ឱ្យយន្តការនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដែលធ្វើឡើងរាល់ឆ្នាំត្រៀម៩ខែ ដែលចុះឈ្មោះមែនទែននៅខែតុលារយៈពេល ២០ថ្ងៃ គឺចង់ឱ្យក្លាយទៅជាយន្តការមួយប្រចាំជីវិតប្រជាពលរដ្ឋខ្មែរ ។ កុំឱ្យពេលចុះឈ្មោះបោះឆ្នោតម្តងៗមានបញ្ហាជាប់រហូត ។ ខុប់សែល ចង់ឱ្យប្រជាពលរដ្ឋនៅពេលដែលមានអាយុ ១៨ឆ្នាំ ពេលមានការប្តូរអាស័យដ្ឋានទៅកន្លែងឃុំសង្កាត់ចុះឈ្មោះខ្លួនឯងដោយស្វ័យប្រវត្តិ ក្នុងឋានៈជាពលរដ្ឋដែលមានការទទួលខុសត្រូវមានកាតព្វកិច្ចត្រូវធ្វើ ។ សំបុត្រកំណើតអត្រានុកូលដ្ឋាន យើងមានក្រុមប្រឹក្សាឃុំសង្កាត់រួចហើយ សូមឱ្យក្រុមប្រឹក្សាឃុំសង្កាត់មានទម្លាប់ជាមួយប្រជាពលរដ្ឋ យើងកើតឡើងមានសំបុត្រកំណើត សំបុត្ររៀបអាពាហ៍ពិពាហ៍ សំបុត្រមរណៈភាព ដើម្បីឱ្យពលរដ្ឋដែលកើតឡើងមានក្រដាសកាន់ ហើយមានឈ្មោះនៅក្នុងបញ្ជីចុះឈ្មោះបោះឆ្នោតពេលអាយុ ១៨ឆ្នាំ ។ បែបនេះទើបយើងអាចហៅប្រទេសយើងថា ជាប្រទេសជឿនលឿនមានការអភិវឌ្ឍន៍ និងមានអរិយធម៌ខ្ពស់ ។

**ទី២** ខុប់សែល បានធ្វើការជាមួយក្រសួងមហាផ្ទៃ ៣ខែ នៅឆ្នាំ ២០០៥ ។ ខុប់សែល បានជំរាបឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង ថា ការដែលច្បាប់បោះឆ្នោតចែងថា ត្រូវប្រើអត្តសញ្ញាណប័ណ្ណដើម្បីចុះឈ្មោះបោះឆ្នោត និងបោះឆ្នោត បើសិនជាពលរដ្ឋខ្មែរមិនមានអត្តសញ្ញាណប័ណ្ណ តើយើងធ្វើយ៉ាងម៉េច? ។ ក្រោយមកនៅខែ មករា ឆ្នាំ ២០០៦ ឯកឧត្តម ស ខេង បានបើកយុទ្ធនាការគំហុកមួយ គឺប្រជាពលរដ្ឋខ្មែរចំនួន ១លាន៩សែននាក់ ត្រូវតែបានធ្វើអត្តសញ្ញាណប័ណ្ណនៅឆ្នាំ ២០០៦ ។ យើងមានមោទនៈភាពណាស់ ដោយសារខេត្តដែលខុប់សែលបានឆ្លងកាត់មកទទួលបានលទ្ធផល ៩០%សឹងតែគ្រប់ខេត្ត ។ ប្រជាពលរដ្ឋតែដល់អាយុ ១៨ឆ្នាំត្រូវតែមានអត្តសញ្ញាណប័ណ្ណ ដើម្បីកុំឱ្យមានការកង្វល់ មិនដែលមានប្រជាពលរដ្ឋនៅប្រទេសណាដែលគ្មានអត្តសញ្ញាណប័ណ្ណទេ ។ កាលណាមានឈ្មោះហើយ កុំដូរឈ្មោះទៀត យើងឃើញថា ការដូរឈ្មោះចុះឡើងការខុសអក្ខរាវិរុទ្ធសឹងតែ គជប វង្វេងបញ្ជីចុះឈ្មោះបោះឆ្នោត បញ្ហានេះមាន គឺគ្រប់កន្លែងគ្រប់ខេត្ត ។ ដូច្នេះយើងត្រូវតែធ្វើការអប់រំប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំសង្កាត់ ស្មៀនឃុំសង្កាត់ និងនគរបាលនៅតាមប៉ុស្តិ៍ ប៉ូលីសនៅពេលដែលធ្វើអត្តសញ្ញាណប័ណ្ណ ត្រូវធ្វើឱ្យបានម៉ត់ចត់ ។

**ទី៣** ធ្វើយ៉ាងណាឱ្យយុទ្ធនាការឃោសនាបោះឆ្នោតម្តងៗប្រកបដោយសុវត្ថិភាព ។ បើឈ្នះ គឺឈ្នះដោយទឹកចិត្តប្រជាពលរដ្ឋបោះឆ្នោតឱ្យ មិនមែនឈ្នះដោយការគំរាមគំហែង ការគាបសង្កត់ ដោយយកលុយទិញទឹកចិត្តទេ ។ យើងមានបទពិសោធន៍ ដោយ

កសាងប្រទេសតាំងពីឆ្នាំ ១៩៩៣មក លុះមកដល់ពេលដែលយើងចាប់ផ្តើមឈប់ប្រើអ្វីផ្សេង ក្រៅពីការឈ្នះទឹកចិត្តប្រជាពលរដ្ឋដោយអ្វីដែលធ្វើទៅប្រជាពលរដ្ឋមើលឃើញ គឺបោះឱ្យហើយ ។

ដោយលោកផ្ទាល់បានឆ្លងកាត់ច្រើនខេត្តឃើញថា មានការអភិវឌ្ឍន៍ច្រើន អ្វីដែលនៅជុំវិញមានការប្រសើរជាងមុនឆ្ងាយណាស់ ហើយបើយើងមិនថែរក្សារបស់ទាំងនោះទេ វានឹងបាត់ទៅយ៉ាងលឿនជាទីបំផុត ។

## ០៤. ស្ថានភាពទូទៅនៃការរៀបចំការបោះឆ្នោត ថ្លែងដោយ លោក សេង នេង ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោត ខេត្តកោះកុង

លោកបានលើកឡើងនៅការងារមួយចំនួនកន្លងមក ទាក់ទងនិងការងារបោះឆ្នោត ដោយប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតដោយខ្លួនឯងចំនួន ៤លើក គឺបោះឆ្នោតសកលចំនួន ៣លើក និងអសកលចំនួន ១លើក ។ លោក បានបញ្ជាក់ថា ពីការបោះឆ្នោតមួយទៅការបោះឆ្នោតមួយមានការវិវត្តន៍រីកចំរើនឥតឈប់ឈរប្រកបដោយភាពសេរី យុត្តិធម៌ អព្យាក្រឹត្យ និងតម្លាភាពហើយអាចទទួលយកបាន ។ ទាំងអស់នេះក៏ដោយសារការចូលរួមពីគ្រប់មជ្ឈដ្ឋានជាតិទាំងអស់ និងមានការសហការណ៍យ៉ាងល្អពីស្ថាប័នពាក់ព័ន្ធដូចជាអាជ្ញាធរខេត្ត ស្រុក ក្រុមប្រឹក្សាឃុំ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ អង្គការក្រៅរដ្ឋាភិបាល អង្គការសង្គមស៊ីវិល គណបក្សនយោបាយ ប្រជាពលរដ្ឋ ។ ផ្ទុយមកវិញ បើសិនជាគ្មានការសហការណ៍ល្អ និងការចូលរួមពីស្ថាប័នពាក់ព័ន្ធទាំងអស់នោះទេ គណៈកម្មាការរៀបចំការបោះឆ្នោតមិនអាចសំរេចបាននៅការងារដ៏ធំធេងនោះបានឡើយ ។

លោក ផ្ទាល់ជូសមុខឱ្យគណៈកម្មាការរៀបចំការបោះឆ្នោត សូមសំដែងការអរគុណ និងកោតសរសើរដល់ស្ថាប័នពាក់ព័ន្ធទាំងអស់ដែលបានចូលរួមសហការណ៍ និងសូមឱ្យបន្តនៅការងារដ៏ថ្លៃថ្លានេះតទៅទៀត ដើម្បីឱ្យការងារបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ ២០០៧ ខាងមុខនេះសំរេចបានលទ្ធផលកាន់តែល្អ ហើយអាចទទួលយកបានគ្រប់ៗគ្នា ។

កន្លងមកលេខាធិការដ្ឋានបានជួបបញ្ហាលំបាកជាច្រើន

**ទី១** បញ្ហាភូមិសាស្ត្រ និងមធ្យោបាយធ្វើដំណើរ ដោយខេត្តកោះកុងមានវិសាលភាពដីធំ មានសមុទ្រ កោះ ព្រៃក ភ្នំ មានការិយាល័យចុះឈ្មោះជាង ១៥០កន្លែង មានស្រុកចំនួន ៨ ឃុំចំនួន ៣៣ និងប្រជាពលរដ្ឋរស់នៅជាង ១សែននាក់ ។ ពីឃុំមួយទៅឃុំមួយជាតំបន់ដាច់ស្រយាលឆ្ងាយៗពីគ្នា ការទំនាក់ទំនងមានភាពលំបាកយ៉ាងខ្លាំង ការធ្វើដំណើរត្រូវចំណាយសាហ៊ុយអស់ច្រើន ។ ការដឹកជញ្ជូនសម្ភារៈឯកសារសំរាប់ការបោះឆ្នោតក៏មានការលំបាកខ្លាំង ព្រោះវេលាដឹកជញ្ជូន ពី PEC ទៅ CEC មានពេលតែ ២-៣ថ្ងៃប៉ុណ្ណោះ ហើយថវិការមានដែលបានផ្តល់មកពី គជប មានកំរិតទាប ។ លោក មានការព្រួយបារម្ភខ្លាចថាការងារនេះមិនបានជោគជ័យព្រោះនៅរដូវវស្សាមានភ្លៀងធ្លាក់ច្រើន មានខ្យល់ព្យុះខ្លាំង រលកសមុទ្រធំៗ ។ ចំពោះទីតាំងការិយាល័យបោះឆ្នោតក៏ជួបការលំបាកផងដែរ យើងអាចរកបានតែនៅសាលារៀន វត្តអារាមតែប៉ុណ្ណោះ ក្រៅពីនោះត្រូវជួលគេទាំងស្រុង ។

**ទី២** មិនមានអាគារផ្ទាល់ខ្លួនសំរាប់គណៈកម្មាការរៀបចំការបោះឆ្នោត គឺសូមខ្ចីអាគារអ្នកតំណាងរាស្ត្រ ដោយមានលក្ខណៈតូចចង្អៀត ខេត្តបានផ្តល់ដីកន្លែងមានទំហំ ៣០x៣០ ម៉ែត្រ សំរាប់សាងសង់អាគាររដ្ឋបាល តែមិនមានថវិការសំរាប់ធ្វើការសាងសង់ទេ ។

**ទី៣** ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ច្រើនធ្វើចំពេលដែលស្មៀន និងក្រុមប្រឹក្សាឃុំជាប់រវល់ធ្វើអត្រានុកូលដ្ឋាន អនុវត្តគំរោងកសាងភូមិ ឃុំ ។ ករណីមួយទៀតអនុវត្តលើមាត្រា ៥៣ចាស់ ដែលបានអនុវត្តប្រចាំឆ្នាំកន្លងមក ហើយជួប

បញ្ហាជាច្រើន គឺក្រុមប្រឹក្សាឃុំថា ការងារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះជាការងាររបស់ស្មៀន មិនមែនជាការងាររបស់ឃុំទេ ព្រោះស្មៀនមានប្រាក់ឧបត្ថម្ភ ។

ជាចុងបញ្ចប់លោកសូមថ្លែងអំណរគុណដល់អង្គប្រជុំទាំងមូល ដែលបានបើកការប្រជុំនេះ ដើម្បីស្វែងយល់ និងរកគ្រប់វិធីសាស្ត្រទាំងអស់ ដើម្បីកាត់បន្ថយទំនាស់ទាំងឡាយដែលបានកើតមានកន្លងមកក្នុងការបោះឆ្នោត និងធ្វើឱ្យការបោះឆ្នោតឈានឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យសំរាប់ជាតិយើងទាំងមូល ។

លោក **ឱក សេរី សោភក្តិ** បានមានប្រសាសន៏ថា របាយការណ៏ ខប់សែល គឺជារបាយការណ៏មួយដែលផ្សព្វផ្សាយខ្លាំងជាងគេ ព្រោះមានជំនួយពី UNDP ច្រើនណាស់ ។ ដោយខប់សែលបានធ្វើសហប្រតិបត្តិការណ៏ល្អជាមួយខាង SEILA ខាង PLAU ធ្វើឱ្យរបាយការណ៏នេះបានទៅដល់ ព្រះមហាក្សត្រ សម្តេចប្រធានព្រឹទ្ធសភា សម្តេចប្រធានរដ្ឋសភា សម្តេចនាយករដ្ឋមន្ត្រី គណបក្សនយោបាយទាំងអស់ ស្ថាប័នរដ្ឋ ស្ថាប័នក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ អាជ្ញាធរខេត្ត បានទទួលរៀងរាល់ខែ ។ អ្វីដែលអង្គប្រជុំមានប្រសាសន៏នឹងចូលទៅក្នុងកំណត់ហេតុទាំងអស់ ហើយនិងបានអានគ្រប់ខេត្តឆ្លងគ្នាទៅវិញទៅមក ដើម្បីឱ្យដឹងថា តើខេត្តនីមួយៗមានបញ្ហារបស់ខ្លួនយ៉ាងណា ។

## ០៥. មតិរបស់អ្នកចូលរួម ដែលបង្ហាញអំពីការប្រឈមទាំងឡាយក្នុងយន្តការរៀបចំការបោះឆ្នោត ក្នុងបរិបទ ខេត្តកោះកុង

លោក **សុប ហ៊ួសេន** មេឃុំស្ទឹងវែង ស្រុកស្មាច់មានជ័យ តំណាងគណបក្សប្រជាជនកម្ពុជា ខេត្តកោះកុង បានឯកភាពទាំងស្រុងលើប្រសាសន៏ លោក ឱក សេរី សោភក្តិ ដែលបានលើកឡើងពីការងារជាតិយើងដែលរៀបចំដោយខ្លួនឯង ។ ទោះបីមានការក្រលំបាកយ៉ាងណាក៏បានជាគំរូមួយទៅពាសពេញអន្តរជាតិដើម្បីឱ្យគេទទួលស្គាល់ថា យើងទើបតែងើបចេញពីសង្គ្រាមដ៏រ៉ាំរ៉ៃ ហើយចេញពីបាតដៃទទេ តែយើងអាចរៀបចំបានល្អប្រសើររហូតដល់អន្តរជាតិទទួលស្គាល់ ។ លោក ផ្ទាល់ត្រេកអរណាស់ចំពោះជាតិយើង និងថ្នាក់ដឹកនាំកំពូលៗ ដែលមានស្មារតីបំរើជាតិលើឆាកអន្តរជាតិ ។

លោក បានមានប្រសាសន៏អំពីវិបត្តិ និងឧបសគ្គខ្លះៗដែលរាំងស្ទះដល់ការងារបោះឆ្នោតមិនឱ្យមានការរីកចំរើន ដោយសារគណបក្សនយោបាយមួយចំនួនបានស្តាប់ឮនៅតាមវិទ្យុ ក៏ដូចជាព័តិមានផ្សេងៗថា យើងនិងមានទំនាស់ មានអំពើហិង្សាបន្តិចបន្តួចដែលលើកឡើងជាធំរហូតដល់ចោទទៅគណបក្សនេះអាក្រក់ គណបក្សនេះល្អ គឺតែងតែមាន ។ ដោយឡែកនៅក្នុងស្រុកស្មាច់មានជ័យមិនដែលឃើញទេរយៈពេលបោះឆ្នោតទាំង ៤លើក នេះ គឺបានសេចក្តីសុខ សន្តិភាព និងមានការរីកចំរើន ។ យើងកត់សម្គាល់ឃើញថាលទ្ធផលមានការឯកភាពពីគណបក្សនយោបាយធំៗ និងអង្គការនានាដែលជាអ្នកសង្កេតការណ៏លើការងារបោះឆ្នោត ។

លោក មានការព្រួយបារម្ភចំពោះការបោះឆ្នោតនៅថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០០៧ នេះ គឺកង្វល់ពីការផ្លាស់ប្តូរប័ណ្ណបោះឆ្នោតដោយសារ គជប កែប្រែឈប់យកប័ណ្ណបោះឆ្នោតកន្លងមកដោយប្តូរមកយកអត្តសញ្ញាណប័ណ្ណវិញ ។ ដោយលើកមុនការបោះឆ្នោតយើងបានយកប័ណ្ណបោះឆ្នោតសម័យអ៊ុនតាក់ រហូតដល់ឆ្នាំ ១៩៩៨ ២០០២ ២០០៣ យើងយកឯកសារបោះឆ្នោតជាទម្រង់ចាស់ ។ មកដល់ពេលនេះយើងរៀបចំជាថ្មីតាំងពីថ្ងៃទី ០១-២០ ខែតុលានៅទូទាំងប្រទេស ។ នៅឃុំស្ទឹងវែង ខេត្តកោះកុង ការពិនិត្យ និងចុះឈ្មោះបោះឆ្នោតធ្វើមិនទាន់បានគ្រប់ជ្រុងជ្រោយនៅឡើយទេ ដោយមានរយៈពេលខ្លីពេក ហើយប្រជាពលរដ្ឋមានជីវភាពក្រលំបាក គាត់ផ្លាស់ទីកន្លែងមានការចំណាកស្រុក ២-៣ខែទៅតំបន់ផ្សេង ។ កាលដែលលោកប្រធានលេខាធិការដ្ឋានបាន

មានប្រសាសន៍ថា ឃុំខ្លះថាជាបញ្ហារបស់ស្មៀន តែនៅឃុំស្ទឹងវែង គឺមានការយកចិត្តទុកដាក់ប្រគៀកស្មាគ្នាចំពោះមេឃុំ និងជំទប់ ឱ្យតែទំនេរចុះដល់ផ្ទះប្រជាជន គឺមានការសហការណ៍គ្នាល្អណាស់ ។ លោក មានការព្រួយបារម្ភដោយសង្កេតឃើញថា មានខុសឈ្មោះ អក្ខរាវិរុទ្ធ អាយុ ទិន្នន័យផ្សេងៗជិត ៥០% ចំពោះអ្នកដែលនៅសល់ពិនិត្យមិនទាន់បានគ្រប់ផង ទំរាំតែអ្នកដែលចេញទៅក្រៅទៀត គឺមិនអាចទាន់ទេ ។

លោក បានមានសំណួរថា នៅពេលដែលប្រជាពលរដ្ឋមកបោះឆ្នោតនៅថ្ងៃ ០១ខែមេសា ឆ្នាំ ២០០៧ ។ គេចោទថា លោក មានឈ្មោះបោះឆ្នោត ៣-៤លើកមកហើយ ឥឡូវពេលនេះម៉េចក៏មិនបានបោះឆ្នោត គ្រាន់តែខុសឈ្មោះបន្តិចបន្តួចដែល លោក មិនបាននៅ ។ សូមឱ្យអង្គប្រជុំមេត្តាដោះស្រាយ និងរកឱ្យឃើញលទ្ធផលនៅពេលបោះឆ្នោតនៅថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០០៧ ដើម្បីឱ្យដឹងថា ប្រជាពលរដ្ឋមិនបានកែឈ្មោះមែន ប៉ុន្តែមូលដ្ឋាននៅក្នុងភូមិ ឃុំ ដឹងថាគាត់បានបោះឆ្នោត ២-៣ដង រួចមកហើយ ដូច្នេះគាត់មានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត ។

លោក **ចិន សុផល** តំណាងគណបក្ស សមរង្ស៊ី និងជាមេឃុំអូរបាក់រទេះ ស្រុកកំពង់សីលា ខេត្តកោះកុង យោងតាមបទពិសោធន៍ដែលបានឃើញផ្ទាល់នៅមូលដ្ឋាន លោកបានលើកបញ្ហាខ្លះដាក់ជូនអង្គប្រជុំ

**ទី១** ការស្នាក់នៅបណ្តោះអាសន្នរបស់ប្រជាពលរដ្ឋ ដែលមកពីខេត្តផ្សេងៗ ហើយគាត់រស់នៅឃុំនានាក្នុងខេត្តកោះកុង ។ ភាគច្រើនប៉ូលីសមិនចេញប័ណ្ណស្នាក់នៅឱ្យ ដែលជាបញ្ហាដល់ការចុះឈ្មោះបោះឆ្នោត គឺគាត់មិនមានអត្តសញ្ញាណដែលអាចយកទៅចុះឈ្មោះបោះឆ្នោត ហើយគាត់ក៏មិនអាចធ្វើអត្តសញ្ញាណប័ណ្ណបានដែរ ។ ឥឡូវយើងយកអត្តសញ្ញាណប័ណ្ណសំរាប់បោះឆ្នោតនាំឱ្យបញ្ហាមួយចំនួនគរលើប៉ូលីស ដែលមិនព្រមចេញប័ណ្ណលឿងឱ្យ ។ បើនៅស្រុក លោក ប័ណ្ណលឿងមានការទារលុយពី ៨-១០ ដុល្លា ហើយមានចេញឱ្យមួយៗ ប៉ុន្តែនៅកន្លែងសំងាត់ កន្លែងដែលអស់លុយមិនមែនចេញឱ្យដោយជំហរដល់ប្រជាពលរដ្ឋទេ ។

**ទី២** ទាក់ទងនិងការចុះឈ្មោះនៅតែមានការរើសអើងជានិច្ច អ្នកណាដែលមិនមែនជាខ្សែគណបក្សកាន់អំណាច គឺពិបាកនិងចុះឈ្មោះ ។ មន្ត្រីចុះឈ្មោះរកលេសនេះលេសនោះ ដោយប្តូរការិយាល័យទៅនេះទៅនោះ ធ្វើឱ្យប្រជាពលរដ្ឋរត់តាមអ្នកចុះឈ្មោះមិនទាន់ ។ លោក ក៏ជាអ្នកចុះឈ្មោះដែរ នៅក្នុងឃុំរបស់លោកចុះឈ្មោះឡើងជិតដល់ ២ការិយាល័យ លោក មិនបានរើសអើងអ្វីទាំងអស់ ឱ្យតែជាពលរដ្ឋខ្មែរ ហើយបានស្នាក់នៅក្នុងឃុំនេះច្បាស់លាស់ ។ លោកបានទទួលរបាយការណ៍ថា នៅឃុំដ៏ទៃទៀតមានការរើសអើងយ៉ាងច្រើនទាក់ទងនិងការចុះឈ្មោះ គឺប្រកាន់គណបក្សកាន់អំណាចមានឱកាសគ្រប់គ្រាន់ក្នុងការច្បាមយកចុះដល់គ្រប់កន្លែង តែបើអ្នកណាមាននិន្នាការរបស់ខ្លួន គឺត្រូវបានចុះឈ្មោះដោយប្រុងប្រយ័ត្នជាទីបំផុត ប៉ុន្តែបើអ្នកនោះមើលទៅឃើញថា មិនមែនជាគណបក្សរបស់ខ្លួនទេ អ្នកនោះត្រូវបានរើសអើងយ៉ាងធ្ងន់ធ្ងរ ។

**ទី៣** ប័ណ្ណព័ត៌មានមិនបានចែកដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយទេនៅខ្វះច្រើន ។ ចំពោះឈ្មោះខ្មោចក៏មានច្រើន មានប្រជាពលរដ្ឋខ្លះចេញទៅស្រុកផ្សេង ហើយចុះឈ្មោះនៅស្រុកនោះ ប៉ុន្តែឈ្មោះនៅបញ្ជីនៅស្រុកចាស់ គេរក្សានៅដដែល ទាល់តែស្លាប់ពិតប្រាកដទើបអាចលុបចេញ ។ បញ្ហានេះហើយដែលធ្វើឱ្យចំនួនកើនឡើងខ្ពស់ ធាតុពិតការបោះឆ្នោតនៅខេត្តកោះកុងចុះឈ្មោះបាន ៥ម៉ឺននាក់ តែអ្នកបោះឆ្នោតបានជាង ៣ម៉ឺនប៉ុណ្ណោះ ។

**ទី៤** ការគំរាមគំហែងជាបញ្ហាធ្ងន់ធ្ងរ មានសមាសភាពដែលជាមន្ត្រីប៉ូលីស មន្ត្រីយោធា គាត់បានដើរយ៉ាងជ្រៅនៅក្នុងរឿងនយោបាយ នាំឱ្យប្រជាពលរដ្ឋមានការភ័យខ្លាច ។ លោកបានជួបប្រជាពលរដ្ឋជាច្រើន ដែលគាត់គិតថាចង់ឈរឈ្មោះ ប៉ុន្តែគាត់ខ្លាច គាត់មិនហ៊ានធ្វើនយោបាយដោយជំហរទេ ព្រោះគាត់រស់នៅតំបន់ជិតសមុទ្រ តំបន់ព្រៃ ជូនកាលមានគេបំភ័យគាត់ ។

ជាសំណូមពរលោកសូមឱ្យអ្នកទាំងអស់គ្នាធ្វើនយោបាយដោយសុច្ចរិក ដោយតម្លាភាព ធ្វើទៅតាមការបញ្ចេញស្មារដៃជូនប្រជាពលរដ្ឋឱ្យឃើញជាក់ស្តែង កុំឱ្យយកផ្លូវវងធីត ដូចជាការគំរាមគំហែងគ្រប់រូបភាព ការបញ្ចុះបញ្ចូល ការទាមទារឱ្យមានការស្បថស្បែរ ការផ្តល់ជាអំណោយ ។

**ទី៥** ទាក់ទងនិងការរើសអាងចំពោះគណបក្សនយោបាយ លោក ផ្ទាល់បានទៅប្រជុំ ដោយមានវត្តមាន ឯកឧត្តម សម រង្ស៊ី ផងដែរ តែឯកឧត្តមមិនទាន់មកដល់ មានប៉ូលីសមួយក្រុមទៅឃាត់មិនឱ្យប្រជុំ ។ លោកផ្ទាល់បានសួររកលិខិតស្នាមថា អំណាចថ្នាក់ណាដែលចេញឱ្យឃាត់ប៉ុន្តែមិនមាន លិខិតស្នាមអ្វីទាំងអស់ គេគ្រាន់តែនិយាយពាក្យមួយម៉ាត់ថា បើមិនឈប់ប្រយ័ត្នមានបញ្ហា ។ នេះគឺជារំលោភសិទ្ធិនយោបាយ សិទ្ធិជួបជុំ សិទ្ធិប្រជុំគ្នា ។ បើសិនជាគ្មានវត្តមានអ្នកយល់ច្បាប់ទំលាប់ទេ អង្គប្រជុំនោះប្រាកដជាមិនអាចធ្វើទៅបានទេ ។ ដើម្បីឱ្យគណបក្សមានសិទ្ធិស្មើគ្នា លោក បានសំណូមពរយ៉ាងទទូចទៅខាងប៉ូលីស ខាងស្នងការ ដើម្បីកុំឱ្យមានបញ្ហានេះទៀត ។

ដោយផ្អែកទៅលើបទពិសោធន៍កន្លងមក ទាក់ទងរឿងការបោះឆ្នោត និងរាប់សន្លឹកឆ្នោតកន្លងមកការិយាល័យមួយដាក់តែភ្នាក់ងារនៅខាងក្នុង និងខាងក្រៅបន្តិចបន្តួច ហើយប្រជាពលរដ្ឋត្រូវបានដេញចេញយ៉ាងឆ្ងាយពីការិយាល័យ គឺមិនមានតម្លាភាពទេ ។ លោក ក៏បានសំណូមពរទុកជាមុនសូមឱ្យប្រជាពលរដ្ឋបានឃើញ ឬបានឮ នៅជុំវិញការិយាល័យផង ដើម្បីជាការកក់ក្តៅដល់អ្នកសង្កេតការណ៍ ដល់ភ្នាក់ងារនយោបាយដែលមានសម្លេងតិច ។

ទាក់ទងនិងរឿងកាលដែលប្រជាជនដាក់ឈ្មោះច្រើន ព្រោះគាត់ខ្លាចតាំងពីជំនាន់ប៉ុលពតមក ឈ្មោះពិតគេមិនហ៊ានដាក់ទេខ្លាចគេស្គាល់ប្រវត្តិ នាំឱ្យនៅក្នុងបញ្ជីមួយដាក់ឈ្មោះមួយតាំងពី ១៩៩៣ រហូតមកដល់ ២០០៣ មកដល់ឥឡូវដាក់ឈ្មោះមួយទៀត ។ អត្តសញ្ញាណប័ណ្ណខុសជាមួយនិងបញ្ជីបោះឆ្នោតទាំងអស់ មានការកែច្រើនណាស់ ។

ជានិច្ចជាកាលឱ្យតែមានការបោះឆ្នោត រាប់សន្លឹកឆ្នោត តែងតែមានបញ្ហា ដូចជាបាតុកម្មជាដើម បញ្ហានេះមកពីមានការរាប់បន្ទំសន្លឹកឆ្នោត ។ លោកបានលើកឧទាហរណ៍នៅឃុំស្វាយចញ្ជឹម ខេត្តកំពង់ស្ពឺ រាប់ម្តងគណបក្សប្រជាជនឈ្នះ រាប់ឡើងវិញម្តងទៀត គណបក្ស សមរង្ស៊ី ឈ្នះ បញ្ហានេះមកពីការរាប់លឿន ហើយភ្នាក់ងារគណបក្សនយោបាយមើលមិនបានគ្រប់ជ្រុងជ្រោយដោយសារការភ័យខ្លាច ។ ដើម្បីបង្ការទំនាស់នេះ លោក សូមសំណូមពរឱ្យរាប់សន្លឹកឆ្នោតយឺតៗ ដោយមានស្មារតីទទួលខុសត្រូវ មានតម្លាភាព ហើយផ្សាយឱ្យប្រជាពលរដ្ឋបានឮនៅខាងក្រៅផង ។

កាលបោះឆ្នោតឆ្នាំ ២០០៣ លោក ផ្ទាល់ក្នុងនាមតំណាងគណបក្សមួយ គ្រាន់តែទៅមើលជិតការិយាល័យ មានប៉ូលីសដេញចំងាយ ១០០ ម៉ែត្រពីការិយាល័យ បើមិនចេញប៉ូលីសនឹងចាប់ដាក់ខ្នោះ ។ លោក គ្រាន់តែចង់ដើរឱ្យភ្នាក់ងារគណបក្សមានស្មារតីរឹងមាំមើលសន្លឹកឆ្នោតឱ្យច្បាស់ ។ លោក សំណូមពរកុំឱ្យមានបញ្ហានេះកើតឡើងទៀតមិនថាតែតំណាងគណបក្សនយោបាយទេ ប្រជាពលរដ្ឋក៏ជាតំណាងសន្លឹកឆ្នោតរបស់គាត់ដែរ សូមឱ្យបាននៅស្តាប់ជិតការិយាល័យផង ។

លោក **សេង នេង** បានឆ្លើយតបទៅនិងសំណួររបស់សមាជិកនៃអង្គប្រជុំ **ទី១** ការផ្លាស់ប្តូរប័ណ្ណបោះឆ្នោត រឿងនេះគឺធ្វើទៅតាមនីតិវិធីច្បាប់ ដោយពីមុនយើងអាចយកប័ណ្ណសំគាល់សំរាប់ទៅបោះឆ្នោតបាន ប៉ុន្តែនៅឆ្នាំ ២០០៧ យើងយកអត្តសញ្ញាណប័ណ្ណសំរាប់បោះឆ្នោតវិញ ។ **ទី២** មានឈ្មោះដែលខុសហើយបានបោះឆ្នោតតាំងពីឆ្នាំ ១៩៩៨ ២០០២ ២០០៣ កន្លងមក ហើយឥឡូវចង់ឱ្យគាត់ទៅបោះឆ្នោតឱ្យបាននៅឆ្នាំ ២០០៧នេះ យើងមានវិធី ២ បើសិនជាឈ្មោះខុសត្រូវឱ្យគាត់ទៅកែតំរូវ តែបើគាត់មិនបានកែតំរូវត្រូវឱ្យគាត់ទៅបំពេញទម្រង់ ១០១៨ នៅសាលាឃុំ ហើយគាត់អាចកាន់ទម្រង់ ១០១៨ យកទៅបោះឆ្នោតបាន ។

ចំពោះសំណួររបស់លោក ចិន សុផល **ទី១** បញ្ហាប័ណ្ណស្នាក់នៅ នេះជារឿងខាងនគរបាល ប៉ុន្តែ លោក បានជម្រាបអង្គប្រជុំថា ប្រជាពលរដ្ឋគ្រប់រូបអាចចុះឈ្មោះបាន ហើយស្មៀននិងចុះឈ្មោះឱ្យលុះត្រាតែមាន ៤លក្ខខ័ណ្ឌ ទី១ មានសញ្ជាតិខ្មែរ ទី២ មានទីលំនៅក្នុងឃុំ ទី៣ គ្រប់អាយុ ១៨ឆ្នាំ ទី៤ មានអត្តសញ្ញាណសំគាល់នៅពេលចុះឈ្មោះ ។ **ទី២** ការចែកប័ណ្ណព័តិមាន គោលបំណងនៃការចែកប័ណ្ណព័តិមាន ដើម្បីជួយសំរួលដល់អ្នកបោះឆ្នោតដែលមានឈ្មោះនៅក្នុងបញ្ជីចុងក្រោយឱ្យយល់ដឹងច្បាស់ពី លេខរៀង ឈ្មោះ ទិន្នន័យពាក់ព័ន្ធ និងសាមីខ្លួនក្នុងបញ្ជីបោះឆ្នោត លេខកូដ ទីតាំងការិយាល័យ កាលបរិច្ឆេទនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ កាលបរិច្ឆេទ និងពេលវេលានៃការបោះឆ្នោត ព្រមទាំងប្រភេទឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការសំរាប់ប្រើប្រាស់នៅពេលបោះឆ្នោត ។ បើសិនជាមិនបានទទួលប័ណ្ណព័តិមានក៏មិនមានបញ្ហាដែរ ប្រជាពលរដ្ឋអាចទៅបោះឆ្នោតបាន ហើយអ្នកដែលអាចទៅបោះឆ្នោតបាន គឺមាន **២** លក្ខខ័ណ្ឌ **ទី១** មានឈ្មោះក្នុងបញ្ជីបោះឆ្នោត **ទី២** មានអត្តសញ្ញាណប័ណ្ណសំគាល់នៅពេលបោះឆ្នោត ។

ចំពោះបញ្ហាកាលនៅឆ្នាំ ១៩៩៨ លោក មេឃុំអូរបាក់រទេះបានទៅជិតការិយាល័យរាប់សន្លឹកឆ្នោត ហើយប៉ូលីសដេញចេញមិនឱ្យទៅជិត នេះជារឿងត្រឹមត្រូវ ព្រោះលោកមេឃុំមិនមានប័ណ្ណសំគាល់ថា ជាអ្នកសង្កេតការណ៍ ដូច្នេះ លោក មិនមានសិទ្ធិចូលទៅការិយាល័យរាប់សន្លឹកឆ្នោតបានទេ ។

លោក **ឱក សេរី សោភក្តិ** បានជំរាបបន្ថែមទៅអង្គប្រជុំចំពោះបញ្ហារបស់លោកមេឃុំអូរបាក់រទេះ និងការឆ្លើយតបរបស់លោក សេង នេង ថា នៅក្នុងហ្គឹងមាននីតិវិធី នៅថ្នាក់ជាតិក៏បានពិនិត្យលើនីតិវិធីនេះដែរ ។ អ្វីដែលមាននីតិវិធីនៅក្នុងហ្នឹង ត្រូវតែគោរពទៅតាមនីតិវិធីទាំងអស់គ្រប់ដំណាក់កាលនៃការបោះឆ្នោត ទាំងការចុះឈ្មោះ យុទ្ធនាការឃោសនា ការបោះឆ្នោត រាប់សន្លឹកឆ្នោត ការប្រកាសលទ្ធផលជាដើម ។ យើងមានឯកសារនេះជាគោល ហើយអ្វីដែលមាននៅក្នុងបទបញ្ជា និងនីតិវិធី យើងត្រូវតែគោរពទាំងអស់គ្នា ទើបអាចនិយាយគ្នាបានថា អ្វីដែលអាចធ្វើបានហើយអ្វីមិនអាចធ្វើបាន ។

លោក **សំឃិត វៀន** ស្នងការនគរបាលខេត្តកោះកុង បានលើកឡើងពីស្ថានភាពទូទៅនៅខេត្តកោះកុង ចំពោះការផ្តល់អត្តសញ្ញាប័ណ្ណជូនដល់ប្រជាពលរដ្ឋ ។ នៅឆ្នាំ ២០០៦ ខាងការិយាល័យជំនាញដែលទទួលបន្ទុកកិច្ចការផ្តល់អត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋ គឺបានខិតខំតាមការកំណត់របស់ក្រសួងមហាផ្ទៃ ក៏ដូចជាអគ្គស្នងការដ្ឋាននគរបាលជាតិ ។ ថ្នាក់ដឹកនាំបានដាក់បញ្ជាយ៉ាងគំហុកដើម្បីសំរេចឱ្យបានជោគជ័យលើការផ្តល់អត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋគ្រប់គ្នា២ ចំពោះអ្នកដែលគ្រប់អាយុ។ ក្រោយពីទទួលបានផែនការពីថ្នាក់ដឹកនាំក្រសួង ក៏ដូចអគ្គស្នងការនគរបាលជាតិ យើងបានខិតខំប្រឹងប្រែងរហូតដល់ខែធ្នូយើងបានបញ្ចប់សព្វគ្រប់ ដោយបានបំពេញបែបបទជូនប្រជាពលរដ្ឋគ្រប់ស្រុកទាំងអស់នៅខេត្តកោះកុង ។ យើងបានចែកជូនជាដំណាក់កាលចំពោះអត្តសញ្ញាណប័ណ្ណដែលបានផលិតរួចហើយ ដោយបានផ្តល់ជូនប្រជាពលរដ្ឋជាបណ្តើរ២ ។

នៅក្នុងខែធ្នូ ឆ្នាំ២០០៦ យើងទើបតែទទួលបានអត្តសញ្ញាណប័ណ្ណចំនួន ៥ ០០០សន្លឹកទៀត ដែលទើបតែផលិតរួច ហើយក្រុមហ៊ុនផ្តល់ជូនទៅខាងស្នងការដើម្បីធ្វើការត្រួតពិនិត្យ និងប្រគល់ជូនសាលាខេត្តសំរាប់ជូនឯកឧត្តមអភិបាលខេត្តចុះហត្ថលេខា ។ ឥឡូវនេះខាង លោក មិនទាន់ធ្វើបានចប់សព្វគ្រប់ទេនៅសល់ ២ ៥០០សន្លឹក ប៉ុន្តែជាគោលដៅចំនួន ៥ ០០០សន្លឹក នេះ ត្រូវធ្វើឱ្យចប់សព្វគ្រប់ ដើម្បីឱ្យប្រជាពលរដ្ឋបានទទួលនៅចុងឆ្នាំ ២០០៦នេះ ។

លោក បានជំរាបបន្ថែមពីផលលំបាកជារួមលើការបំពេញបែបបទ ក៏ដូចជាការផ្តល់អត្តសញ្ញាណប័ណ្ណ ដែលបានផលិតរួចហើយ ជូនប្រជាពលរដ្ឋដើម្បីប្រើប្រាស់ជាផ្លូវការ ។ ខាងកិច្ចការជំនាញដែលទទួលបន្ទុកមានផលលំបាក **ទី១** បញ្ហាផ្លូវធ្វើដំណើរកន្លងមកយើងបានបង្កើតស្ថានីយ៍ផ្តល់អត្តសញ្ញាណប័ណ្ណតាមឃុំ ហើយការធ្វើដំណើរជួនកាលទៅដល់តំបន់ដាច់ស្រយាល គឺមានការ

ពិបាកណាស់ តែអ្វីដែលយើងសំរេចបាន គឺជាការខិតខំ និងជាការទទួលខុសត្រូវរបស់សមត្ថកិច្ចផ្នែកជំនាញ ។ លោក ក៏ទទួលស្គាល់នូវចំណុចខ្វះខាត ចន្លោះ ប្រហោងមួយចំនួន ដូចជា មន្ត្រីផ្តល់អត្តសញ្ញាណប័ណ្ណមានអ្នកខ្លះធ្វើមិនសមរម្យ អនុវត្តន៍មិនគប្បី មានបញ្ហាយកលុយកាក់ ។ លោក នឹងខិតខំកែសំរួលបញ្ហានេះជាបណ្តើរៗ ដើម្បីកុំឱ្យមានបញ្ហា និងបំបាត់ចោលនៅបញ្ហានេះ ។

ទាក់ទងនិងបញ្ហា លោក ចិន សុផល ដែលលើកឡើងថា ខាងប៉ូលីសមិនចុះឈ្មោះ មិនផ្តល់សៀវភៅគ្រួសារឱ្យប្រជាពលរដ្ឋ កន្លងមកការផ្លាស់ប្តូរទីលំនៅរបស់ប្រជាពលរដ្ឋ កាលណាគាត់ផ្លាស់ប្តូរទីលំនៅពីខេត្តមួយទៅខេត្តមួយគាត់មានទម្លាប់មួយ គឺមិនផ្ទេរឈ្មោះក្នុងទីលំនៅរបស់គាត់ ។ នេះជាបញ្ហាដែលធ្វើឱ្យមានបញ្ហាឈ្មោះជាន់គ្នាច្រើន ។ អ្វីដែលប្រជាពលរដ្ឋមានស្រាប់ហើយគាត់ផ្លាស់ប្តូរទីលំនៅទៅខេត្តមួយផ្សេងទៀត គាត់អាចយកសៀវភៅគ្រួសារមកចុះឈ្មោះស្នាក់នៅខេត្តមួយទៀតបាន បើសិនជាមានការផ្ទេរនិងមានឯកសារត្រឹមត្រូវថា គាត់បានផ្ទេរ ហើយខាងប៉ូលីសមិនព្រមចុះឱ្យ នេះជារឿងមិនត្រឹមត្រូវទេ ។

ចំពោះបញ្ហាមានការគំរាមគំហែងដល់សុវត្ថិភាព មានការបំភិតបំភ័យដល់ប្រជាពលរដ្ឋ ពីក្រុមប៉ូលីស ទាហ៊ាន ឬក្រុមកំលាំងប្រដាប់អាវុធណាមួយនោះ បើសិនជាមានបញ្ហានេះយើងទាំងអស់គ្នាក៏មិនអាចទទួលយកបានដែរ ជាបញ្ហាដែលមិនត្រឹមត្រូវ ។ កាលដែលមានបញ្ហានេះ លោក ក៏ទទួលស្គាល់ដែរ ព្រោះកំរិតយល់ដឹងរបស់មន្ត្រីនគរបាលមិនស្មើរគ្នាទេ ។ មន្ត្រីខ្លះមានចំណេះខ្ពង់ខ្ពស់ ចេះពិចារណា ចេះវិភាគ ហើយមន្ត្រីខ្លះក៏មិនសូវចេះដឹងពីផ្លូវច្បាប់ ថ្វីត្បិតតែខ្លួនជាមន្ត្រីនគរបាលជាតិក៏ដោយ ។ អ្វីដែលមានការពាក់ព័ន្ធដូចជាការគំរាមគំហែង ការបំផិតបំភ័យ សូមឱ្យមានរបាយការណ៍ មានជាលាយល័ក្ខអក្សរជាពាក្យបណ្តឹងចំពោះបុគ្គលណា មន្ត្រីណាដែលបានប្រព្រឹត្ត ។

លោក **ឱក សេរី សោភក្តិ** បានមានប្រសាសន៍ថា បើសិនជាក្រុមអាជ្ញាធរមានសមត្ថកិច្ចទៅគំរាមគំហែង ដល់ការប្រជុំដែលរៀបចំឡើងដោយគណបក្សនេះ គឺជាការខុស គឺខុសនិងច្បាប់គណបក្ស ខុសនិងច្បាប់កំពូលរដ្ឋធម្មនុញ្ញ ។ នៅពេលដែល ខប់សែលបានដំណើរការមករហូត គឺមានការចោទប្រកាន់ជាច្រើន ប៉ុន្តែអ្នកដែលល្អក៏ទទួល អ្នកមិនល្អទទួលដាក់នៅកន្លែងតែមួយនាំឱ្យយើងមានការពិបាកក្នុងការវែកញែក ។ ដូចដែលលោកស្នងការមានប្រសាសន៍នៅមានកំរិតចំពោះមន្ត្រីរាជាការ ការអប់រំផ្តល់ឱ្យដូចគ្នា ប៉ុន្តែសកម្មភាពដែលអនុវត្តន៍របស់បុគ្គល គឺផ្សេងគ្នា ។ ដើម្បីឱ្យច្បាស់ទាល់តែយើងដឹងថា អ្នកណាធ្វើអ្វី នៅកន្លែងណាឈ្មោះអ្វី ហើយមានសកម្មភាពអ្វីខ្លះ ។ នៅច្រើនខេត្តណាស់ដែលតំណាងសង្គមស៊ីវិល និងតំណាងគណបក្សជំទាស់ឆ្លៀតឱកាសប្រើយន្តការ ខប់សែលនេះដើម្បីរាយការណ៍ទៅថ្នាក់លើ ដូចជាឯកឧត្តមតំណាងសាលាខេត្ត ខាងស្នងការ ខាងអាវុធហត្ថ ខាងប៉ូលីស ហើយផ្តល់ជារបាយការណ៍ផ្ទាល់តែម្តង ។ ពេលត្រឡប់ទៅភ្នំពេញមាន ឯកឧត្តម ហុក ឡុងឌី បានធ្វើការស៊ើបអង្កេតពីរឿងយកលុយកាក់ រឿងទៅសំឡុត គំរាមគំហែងគេ ដោយមិនមានបញ្ហាសោះ ។ រឿងនេះបានរកឃើញ ហើយបានធ្វើការពិន័យដល់មន្ត្រីទាំងអស់នោះ ។

រឿងចែកប័ណ្ណព័តិមាន មានអង្គការសង្គមស៊ីវិលមួយចំនួនបានរាយការណ៍ថា មេភូមិឈ្មោះនេះ នៅភូមិនេះ គាត់យកទៅទុកមិនចែកគេ ហើយខាង គជប ដឹងបានធ្វើការណែនាំ ព្រមទាំងស្តីបន្ទោសដល់មេភូមិទាំងនោះ ។ រាល់បញ្ហាអវិជ្ជមានទាំងអស់សូមឱ្យមានជាលាយល័ក្ខអក្សរ និងសូមច្បាស់ពីឈ្មោះ ទីកន្លែង និងសកម្មភាពដែលបុគ្គលនោះបានប្រព្រឹត្ត ។

លោក **ព្រេន ពិសិដ្ឋ** ជំទប់ទី ១ ឃុំកោះកាពិ ខេត្តកោះកុង តំណាងគណបក្សសមរង្ស៊ី បានមានប្រសាសន៍ថា កន្លងមកការជ្រើសរើសមន្ត្រី CEC ប្រចាំឃុំ គឺមានការខុសពីនីតិវិធី ។ ដោយ លោក បានទទួលលិខិតណែនាំពី PEC បញ្ជូនឱ្យឃុំ ដើម្បីបិទផ្សព្វ ផ្សាយជូនដល់ប្រជាពលរដ្ឋ ឬគ្រូបង្រៀនទាំងឡាយណាដែលមានសមត្ថភាពអាចចូលរួមក្នុងការងារ CEC ប្រចាំឃុំបាន ។ យើងបានកំណត់ទីតាំងធ្វើនៅសាលាឃុំកោះកាពិ កាលបរិច្ឆេទថ្ងៃទី ១០ នឹងមានការចែកពាក្យដល់បេក្ខជនដែលចង់មកដាក់ពាក្យ ថ្ងៃទី

១១ នឹងមានការធ្វើតេស ឬឆ្លើយសំណួរផ្សេងៗជូនទៅមន្ត្រី PEC ដែលទៅជ្រើសរើស CEC ។ មន្ត្រីដែលចុះពីខេត្តទៅមិនបានធ្វើនៅលើទីតាំងដែលឃុំបានកំណត់ទេ គេធ្វើនៅកន្លែងផ្សេង តែអ្នកដែលចង់មកដាក់ពាក្យបានរងចាំនៅសាលាឃុំ ចំពោះវេលាគេរៀបចំធ្វើតែមួយថ្ងៃរួមគ្នាតែម្តង ។ លោកគិតថា នេះជាការជ្រើសរើសដែលមានភាពមិនប្រក្រតី មិនអព្យាក្រឹត្យ គឺមានបក្សពួកនិយម ។

លោក **សេង នេង** បានមានប្រសាសន៍បំភ្លឺទៅលើបញ្ហាជ្រើសរើសមន្ត្រី CEC កន្លងមកនៅ PEC ក៏មានការលំបាកដែរ ព្រោះ គជប ដាក់ពេលវេលាមកខ្លី ដោយកំណត់១ឃុំ២ថ្ងៃ ហើយស្រុកខ្លះមាន ៦ឃុំ អញ្ចឹងនាំឱ្យមានបញ្ហាយើងមិនអាចធ្វើការទាន់ ។ ម្យ៉ាងទៀតគ្រូបង្គោលត្រូវទៅភ្នំពេញវិញដើម្បីរៀនឱ្យទាន់ពេលដែល គជប បានកំណត់ ។ ចំពោះការផ្សព្វផ្សាយក៏មានការលំបាកដែរ ព្រោះថវិការដែល គជប ឱ្យមកមានកំណត់ យើងត្រូវការចំណាយច្រើនក្នុងការផ្សព្វផ្សាយឱ្យគ្រប់ឃុំ ដូច្នេះយើងមិនអាចធ្វើបានទូលំទូលាយទេ ។ ការចុះទៅជ្រើសរើសមន្ត្រី CEC នៅតាមឃុំ គឺមិនមានការលាក់បាំងទេ យើងបានផ្សព្វផ្សាយតាមតំណាងគណបក្ស បើប្រជាពលរដ្ឋណាមានសមត្ថភាពអាចមកដាក់ពាក្យបាន ។

បញ្ហាលំបាកមួយទៀតនៅឃុំខ្លះមានអ្នកមកដាក់ពាក្យតិច ហើយឃុំខ្លះមានចំនួនច្រើន ។ ការជ្រើសរើសនេះ គឺផ្អែកទៅលើសមត្ថភាពជាក់ស្តែង មានប្រជាពលរដ្ឋខ្លះមានសញ្ញាប័ត្រខ្ពស់ដែលធ្វើការមិនកើត ដោយសារគាត់មើលស្រាលលើការងារ ។ ផ្ទុយទៅវិញអ្នកដែលមានសញ្ញាប័ត្រទាបធ្វើការបានល្អ ដោយសារគេខិតខំព្យាយាមធ្វើការងារ ។

លោក បានជំទាស់និងពាក្យថា ការជ្រើសរើសមានការប្រកាន់បក្សពួក ព្រោះការងារនេះឱ្យតែការដាក់ពាក្យតាមបែបបទរដ្ឋបាល និងបំពេញគ្រប់លក្ខខ័ណ្ឌ គឺគេនឹងទទួលយក ។

ឯកឧត្តម **យ៉យ ស៊ើយ** បានមានប្រសាសន៍ថា ឆ្លងតាមរយៈការពិភាក្សាមក គឺបញ្ហាត្រូវតែកើតមាននៅក្នុងសកម្មភាពនៃការអនុវត្តន៍ សំខាន់ដំណោះស្រាយត្រូវតែធ្វើទៅតាមនីតិវិធី ច្បាប់ដែល គជប បានកំណត់ ។ អ្វីដែលស្ថិតនៅក្នុងបញ្ហាដែលកើតឡើងអាចទាក់ទងទៅលើលិខិតបទដ្ឋានទៅលើស្ថាប័នដែលមានសមត្ថកិច្ច និងជំនាញទីមួយៗដែលបានអនុវត្តន៍នូវតួនាទីរបស់ខ្លួន ។

បញ្ហាខ្លះយើងក្តាប់នូវតួនាទីមន្ត្រីពាក់ព័ន្ធមិនបាន ឧទាហរណ៍ រឿងសៀវភៅស្នាក់នៅដែលខាងនគរបាលបានគ្រប់គ្រង ដោយអត្រានុកូលដ្ឋាននៅខេត្តកោះកុងធ្វើមិនចប់ ព្រោះមានប្រជាពលរដ្ឋមួយចំនួនចេញទៅនៅខេត្តផ្សេង ដោយមិនបានសូមផ្ទេរទីលំនៅពីទីនេះទេ តែបានទៅសុំចុះឈ្មោះនៅកន្លែងថ្មី ដែលជាហេតុនាំឱ្យកន្លែងថ្មីមានកំនើនច្រើន ។ បញ្ហាអត្រានុកូលដ្ឋានយើងមិនអាចធ្វើចប់ទេ ។

ទាក់ទងនិងរឿងសិទ្ធិអំណោច ពេលនេះយើងបានអនុវត្តន៍នូវគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ អញ្ចឹងអំណាចក្រុមប្រឹក្សាឃុំជាអំណាចនីតិបុគ្គល ។ មានរូបភាពខ្លះយើងនៅមិនទាន់មានកិច្ចសហការណ៍គ្នាបានល្អ ដើម្បីយល់ដឹងនូវអ្វីដែលជាលិខិតបទដ្ឋានច្បាប់សំរាប់កំណត់នៅក្នុងបញ្ហាការដែលឱ្យយើងទទួលយកដោយមានលិខិតបទដ្ឋានជាសំអាងក្នុងផ្លូវច្បាប់ ។ យើងគួរតែសិក្សា និងកែលម្អលើចំណុចនេះ ។

ក្នុងនាមជាអាជ្ញាធរ ឯកឧត្តម បានសច្ចាថា មិនទទួលយកទេអ្វីដែលមិនយុត្តិធម៌ មិនសមធម៌ មិនតម្លាភាព មិនអភិបាលកិច្ច ។ តាមដែលស្តាប់អង្គប្រជុំមានប្រសាសន៍មក មានចំណុចខ្លះមានបញ្ហា បើសិនយើងយកបញ្ហានោះមកធ្វើការវិភាគឱ្យបានត្រឹមត្រូវថាបើយើងចង់ធ្វើអ្វីមួយ តើយើងត្រូវធ្វើយ៉ាងម៉េច? ឬមានអ្វីខ្លះដើម្បីរៀបចំបង្កើតឱ្យមានវាឡើង ។ យើងត្រូវរៀបរៀងឱ្យទៅជាប្រព័ន្ធមួយដែលស្របច្បាប់ ស្របនិងសកម្មភាព និងការទទួលយកបាន ក្នុងការស្ថាបនារបស់ប្រទេសជាតិយើង ។

លោក **ឱក សេរី សោភក្តិ៍** តាំងនាមឱ្យវិទ្យាស្ថាន CDRI សូមថ្លែងអំណរគុណដល់ឯកឧត្តម អភិបាលរងខេត្ត ដែលបានមានប្រសាសន៍ប្រកបដោយអត្ថន័យ និងខ្លឹមសារយ៉ាងជ្រាលជ្រៅ ។ គ្មានអ្វីដែលរំភើបជាងនេះទេ ដែលខប់សែលចេះតែខំប្រឹងពីខេត្តមួយទៅខេត្តមួយ ដើម្បីកសាងនូវវប្បធម៌នៃការជជែកពិភាក្សាគ្នាត្រង់ទៅត្រង់មក ។

យើងបានឃើញហើយបញ្ហាដែលប្រជាពលរដ្ឋក្រោយចេញពីសង្គ្រាម មានការដូរឈ្មោះ កែឈ្មោះ មានខាងអាជ្ញាធរសរសេរមិនត្រូវទាំងថ្នាក់មូលដ្ឋាន ទាំងខាងប្រជាពលរដ្ឋ ។ ខប់សែល កំពុងតែធ្វើការជាមួយ គជប ហើយការដែលខុសឈ្មោះបន្តិចបន្តួចនៅក្នុងអត្តសញ្ញាប័ណ្ណមិនមានបញ្ហាទេ អាចទៅបោះឆ្នោតបាន កុំឱ្យតែដូរឈ្មោះទាំងមូល គឺមានបញ្ហា ។

យើងក៏កំពុងតែធ្វើការជាមួយដៃគូរអន្តរជាតិ ដើម្បីជួយរាជរដ្ឋាភិបាល ដោយសារការប្តូរឈ្មោះ ដូចដែលលោកសុផល បានមានប្រសាសន៍ លោកគិតថា ហេតុផលមួយ គឺសន្តិសុខផ្ទាល់ខ្លួនដែលយើងទទួលមរតកពីជំនាន់ប៉ុលពតមក ដែលនាំឱ្យប្រជាពលរដ្ឋប្រើឈ្មោះច្រើន ។ យើងមានវិធីពីរដើម្បីកុំឱ្យមានឈ្មោះស្ទួន ទី១ គេស្កេនរូបថត និងម្រាមដៃ ឱ្យតែមានឈ្មោះពីរ រូបថត និងម្រាមដៃដូចគ្នា គេដកចោលតែម្តង ដោយហៅសាម៉ីខ្លួនមកសួរថា ជ្រើសរើសយកមួយណាដែលពិតប្រាកដ។ បើចុះបែបនេះម្តងទៀត ត្រូវទទួលមានទោសចំពោះមុខច្បាប់រដ្ឋ ។ ដោយ គជប មានគំរោងពិនិត្យនិងចុះឈ្មោះបោះឆ្នោតត្រឹមតែ ៦0ម៉ឺននាក់សំរាប់ខែតុលាកន្លងមកនេះ តែពេលចុះមែនទែនបានដល់ ១លាន២សែននាក់ គឺខុស១00% ។

បញ្ហានេះទាល់តែប្រជាពលរដ្ឋចាប់ផ្តើមមានរបៀបរបបមួយក្នុងការរស់នៅ មានប័ណ្ណសំគាល់ខ្លួន អត្តសញ្ញាប័ណ្ណ សំបុត្រកំណើត ប័ណ្ណស្នាក់នៅ ត្រូវតែអនុវត្តន៏ មិនអាចរាយប៉ាយបានទៀតទេ ។ បើរដ្ឋមួយគ្រប់គ្រងប្រជាពលរដ្ឋខ្លួនឯងមិនបាន បើក្រុមប្រឹក្សាឃុំសង្កាត់គ្រប់គ្រងប្រជាពលរដ្ឋមិនបាន យើងនឹងមានបញ្ហាទាំងអស់គ្នា យើងមិនអាចធ្វើផែនការអភិវឌ្ឍន៍ យើងមិនអាចធ្វើសាលារៀន មិនអាចសង់មណ្ឌលសុខភាពបានទេ ព្រោះយើងក្តាប់ចំនួនប្រជាពលរដ្ឋមិនបាន ។

នៅពេលដែលយើងប្រជុំ ខប់សែល ទើបយើងមើលឃើញថា បញ្ហានៅចំពោះមុខត្រូវតែដោះស្រាយ មិនមែនជារឿងរបស់រាជរដ្ឋាភិបាលរបស់គណបក្សនយោបាយ របស់សង្គមស៊ីវិលទេ គឺជារឿងរបស់ប្រជាពលរដ្ឋខ្មែរទាំងអស់គ្នា ។

ជាចុងក្រោយ ខប់សែល សូមអរគុណដល់សមាជិកអង្គប្រជុំទាំងអស់ដែលបានចូលរួមមានមតិយ៉ាងផុលផុស ព្រមទាំងសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ និងទេវតាទាំងមួយម៉ឺន លោក ធាតុសូមឱ្យជួយថែរក្សាយើងទាំងអស់គ្នា ឱ្យប្រកបតែនឹងពុទ្ធពរទាំងប្រាំប្រការ គឺអាយុ វណ្ណៈ សុខៈ ពាលៈ និងបដិភនៈ កុំបីឃ្លានឃ្លាតឡើយ ។